ការព្រួយបារម្ភ ក

## ខ្ញុំមិនប្រាកដថាវាមានតម្លៃក្នុងការប្រែចិត្តនោះទេ ។

- តើបទគម្ពីរ និងគោលការណ៍អ្វីខ្លះមកពី ម៉ូសាយ ២៦ ឬបទគម្ពីរផ្សេងទៀត ដែលអ្នកអាចចែកចាយ ដែលអាចជួយដល់កង្វល់នេះ ?

សូមចាំថា អាលម៉ាខ្លួនឯងបានប្រព្រឹត្តអំពើបាបធ្ងន់ធ្ងរពីមុនក្នុងជីវិតរបស់លោក ហើយបានប្រែចិត្ត ហើយបានទទួលការអភ័យទោសតាមរយៈព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ( សូមមើល ម៉ូសាយ ១១:៥–៧; ១៨:១–៣; ២៦:១៥, ២០ ) ។

- តើអ្នកគិតថា អាលម៉ាអាចចែកចាយអ្វីជាមួយបុគ្គលម្នាក់ដែលមានកង្វល់នេះ ?

សូមសញ្ជឹងគិតពីអ្វីដែលអ្នក ឬបុគ្គលដែលអ្នកស្គាល់បានជួបប្រទះ ពេលអ្នកបានងាកមករកព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ តាមរយៈការប្រែចិត្ត ។

ការព្រួយបារម្ភ ខ

## ហេតុអ្វីខ្ញុំត្រូវសារភាពអំពើបាបរបស់ខ្ញុំ ? ហេតុអ្វីអំពើបាបខ្លះចាំបាច់ត្រូវសារភាពចំពោះថ្នាក់ដឹកនាំបព្វជិតភាព ?

ព្រះអម្ចាស់បានមានបន្ទូលប្រាប់អាលម៉ាថា អស់អ្នកដែលបានធ្វើបាបត្រូវ « ទទួលសារភាពនូវអំពើបាបទាំងឡាយរបស់ខ្លួនចំពោះអ្នក [ អាលម៉ាអ្នកដឹកនាំបព្វជិតភាពរបស់ពួកគេ ] និងចំពោះយើងគឺ [ ព្រះអម្ចាស់ ] » ( ម៉ូសាយ ២៦:២៩ ) ។

- ដោយសារព្រះអម្ចាស់ជ្រាបពីអំពើបាបរបស់យើងរួចហើយ ហេតុអ្វីវាសំខាន់ដែលយើងត្រូវសារភាពចំពោះទ្រង់ ? តើវានឹងផ្តល់ពរជ័យដល់ជីវិតយើងយ៉ាងណា ?

សូមអានសេចក្តីថ្លែងការណ៍ខាងក្រោមពីកូនសៀវភៅ *ដើម្បីកម្លាំងនៃយុវជន* និង អែលឌើរ ស៊ី. ស្កត ហ្គ្រូ អ្នកមានសិទ្ធិអំណាចទូទៅនៃពួកចិតសិបនាក់ ហើយរកមើលការយល់ដឹងអំពីពេលវេលា និងមូលហេតុដែលយើងគួរសារភាពចំពោះប៊ីស្សព ឬប្រធានសាខា ។



> ប៊ីស្សពមានសិទ្ធិទទួលវិវរណៈពីព្រះវិញ្ញាណបរិសុទ្ធស្តីពីសមាជិកក្នុងវួដរបស់លោក រួមទាំងអ្នកផងដែរ ។. . . [ លោក ] អាចជួយអ្នកឲ្យឆ្លងកាត់ដំណើរការប្រែចិត្តតាមរបៀបដែលឪពុកម្តាយរបស់អ្នក ឬអ្នកដឹកនាំផ្សេងទៀតមិនអាចផ្តល់ឲ្យបាន ។ . . .
>
> [ ប្រសិនបើយើងមិនសារភាពទេ នោះយើង ] រែកបន្ទុកនៃអំពើបាបតែម្នាក់ឯង ជាជាងអនុញ្ញាតឲ្យព្រះអង្គសង្គ្រោះដកបន្ទុកនោះចេញ ។ ( ស៊ី. ស្កត ហ្គ្រូ « Why and What Do I Need to Confess to My Bishop? » New Era ខែ តុលា ឆ្នាំ ២០១៣ ទំព័រ ២៨–២៩ )

- តើសេចក្តីថ្លែងការណ៍នេះអាចជួយនរណាម្នាក់ដែលមានកង្វល់អំពីការសារភាពចំពោះថ្នាក់ដឹកនាំបព្វជិតភាពរបស់ពួកគេយ៉ាងដូចម្តេច ?

ការព្រួយបារម្ភ គ

## ខ្ញុំបានប្រព្រឹត្តអំពើបាបច្រើនណាស់ រហូតដល់ព្រះអម្ចាស់មិនអាចអត់ទោសឲ្យខ្ញុំបាន ។

- តើព្រះបន្ទូលរបស់ព្រះអម្ចាស់នៅក្នុង ម៉ូសាយ ២៦:២៩–៣០ អាចជួយដល់កង្វល់នេះបានយ៉ាងដូចម្តេច ? ( អ្នកក៏អាចពិចារណាសិក្សា ធីម៉ូថេ ទី១ ១:១៥; យ៉ូហាន ទី១ ១:៩; ឬ គោលលទ្ធិ និង សេចក្តីសញ្ញា ១៨:១០–១២; ៥៨:៤២–៤៣ ផងដែរ ) ។
- តើដំណើររឿងអ្វីខ្លះក្នុងព្រះគម្ពីរអំពីព្រះអង្គសង្គ្រោះ បង្ហាញពីព្រះទ័យរបស់ទ្រង់ដល់អស់អ្នកដែលព្យាយាមប្រែចិត្ត និងព្រះឆន្ទៈរបស់ទ្រង់ក្នុងការអត់ទោស ?

ការព្រួយបារម្ភ ឃ

## ជម្រើសរបស់អ្នក

សូមគិតអំពីកង្វល់ជាក់ស្តែងមួយទៀត ឬសំណួរដែលនរណាម្នាក់អាចមានអំពីការប្រែចិត្ត ។ សូមសិក្សា « ការប្រែចិត្ត » ឬ « ការសារភាព » នៅក្នុងសេចក្តីណែនាំដល់បទគម្ពីរទាំងឡាយ ( scriptures.ChurchofJesusChrist.org ) ដោយស្វែងរកសេចក្តីពិតទាំងឡាយដែលអាចជួយបាន ។ អ្នកក៏អាចរំឭកបទគម្ពីរដែលទាក់ទងនឹង « ការប្រែចិត្ត » ឬ « ការសារភាព » នៅក្នុងTopical Guide ( ChurchofJesusChrist .org ) ។, វាក៏អាចមានប្រយោជន៍ផងដែរក្នុងការសិក្សា « ការប្រែចិត្ត » នៅក្នុងកូនសៀវភៅ ដើម្បីកម្លាំងនៃយុវជន ហើយសញ្ជឹងគិតអំពីអ្វីដែលអ្នកដឹងអំពីព្រះអម្ចាស់ ដែលអាចនឹងជួយ ។

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៣ by Intellectual Reserve, Inc. All rights reserved.
PD60013873_258_221-teacher_handout-1